អេស៊ីលីដា
ACLEDA BANK

# សេចក្តីជូនដំណឹង
## ស្តីពី
# ការបែងចែកភាគលាភ

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេច នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៤ របស់ធនាគារ អេស៊ីលីដា នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា សម្រេចបែងចែកភាគលាភ សម្រាប់ប្រាក់ចំណេញក្នុង ឆ្នាំ២០២៣ ជូនដល់ភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ប្រភេទភាគលាភដែលត្រូវបែងចែក | **: សាច់ប្រាក់** |
| ២. | រយៈពេល នៃភាគលាភ | **: ប្រចាំឆ្នាំ** |
| ៣. | អនុបាត នៃការបែងចែកភាគលាភ | **: ១០%** |
| ៤. | ភាគលាភសរុបដែលត្រូវបែងចែក | **: ៦០.៨៥០.៥២៤.៣២៧,៦៣ រៀល** |
| ៥. | ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | **: ១៤០,៤៧៩៥ រៀល** |
| ៦. | កាលបរិច្ឆេទអិចឌីវីដិនដ៍ | **: ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤** |
| ៧. | កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ (កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ) | **: ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤** |
| ៨. | កាលបរិច្ឆេទទូទាត់ភាគលាភ | **: ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤** |

**<u>បញ្ជាក់៖</u>**

- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភដូចការកំណត់ខាងលើ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក (Record Date) នៅ**ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤**។
- ភាគហ៊ុនិកដែល**លក់**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤ គឺនៅតែមានសិទ្ធិ**ទទួលបានភាគលាភនេះដដែល។
- ភាគហ៊ុនិកដែល**ទិញ**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤ គឺមិនមានសិទ្ធិ**ទទួលបានភាគលាភនេះទេ។
- ការទូទាត់ភាគលាភនឹងចាប់ផ្តើមពី**ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤** នៅរៀងរាល់ថ្ងៃធ្វើការ។

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (**ភ្នាក់ងារ RTP**) ដូចខាងក្រោម៖

- លោក ហួត សុភី ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh
- លោក កែន រិទ្ធពុទ្ធា អ្នកឯកទេសបឋមប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦១៣
  - អ៊ីម៉ែល: ken.rithputhea@acledabank.com.kh
- លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ បុគ្គលិកជាន់ខ្ពស់ផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - អ៊ីម៉ែល: op.rtp@acledabank.com.kh

ថ្ងៃពុធ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**